ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ...ធ១៣...០២០...៤៧៨...ស.ធ.ណ

*ថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០*

## សេចក្តីជូនដំណឹង
## ស្តីពី លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ លើកទី៥១

នៅថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ២:៣០ រសៀល ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុលើកទី៥១ ក្រោមអធិបតីរបស់ ឯកឧត្តម ទេសាភិបាល និងជាប្រធានគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ។ អង្គប្រជុំបានពិភាក្សាលើបច្ចុប្បន្នភាពនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក វឌ្ឍនភាព និងបញ្ហាប្រឈមនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ព្រមទាំងគោលនយោបាយរូបិយវត្ថុសម្រាប់អនុវត្តនាគ្រាខាងមុខ។

ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃនិងលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុសម្រាប់ត្រីមាសបន្ទាប់ គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ បានសម្រេចលើជំហរគោលនយោបាយរូបិយវត្ថុ ដូចខាងក្រោម ៖

១/- ធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់តាមការចាំបាច់ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់

២/- បន្តផ្តត់ផ្គង់សន្ទនីយភាពជាប្រាក់រៀលតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ក្នុងទំហំសមស្រប និង

៣/-បន្តពង្រឹងការប្រើប្រាស់ប្រាក់រៀលឱ្យបានទូលំទូលាយ តាមវិធានការដែលមានស្រាប់ និងវិធានការតាមយន្តការទីផ្សារ។

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**
**ប្រធានគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ**

ជា-ចាន់តូ

**ចម្លងជូន ៖**
- សមាជិកគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ
- ឯកសារ-កាលប្បវត្តិ

ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧